Asian American Health Initiative

# សន្លឹកព័ត៌មានរោគមហារីកពោះវៀនធំ

## តើរោគមហារីកពោះវៀនធំគឺជាអ្វី ?

រោគមហារីកពោះវៀនធំ កើតឡើងពីការរីកធំតូចៗ ឬ **ដុំសាច់ (polyps)** នៅក្នុងពោះវៀនធំ ឬចុងពោះវៀន។ ដុំសាច់គឺជាជាលិកាមិនធម្មតាដែលរីកធំធាត់នៅក្នុងរាងកាយរបស់អ្នក ។ ដុំសាច់ភាគច្រើនបំផុតមិនមានរោគមហារីក និងមិនមានគ្រោះថ្នាក់នោះទេ ។ តែក្នុងកំឡុងរយៈពេលមួយ ដុំសាច់ប្រភេទមួយចំនួនអាចប្រែប្រួលទៅជារោគមហារីក ។




## កត្តាប្រថុយគ្រោះថ្នាក់

- **អាយុលើស 50 ឆ្នាំ**
- **ប្រវត្តិគ្រួសារ**
- **ឃើញមាន ឬធ្លាប់មានដុំសាច់កាលពីមុននៅក្នុងពោះវៀនធំ និងចុងពោះវៀន**
- **ការតមអាហារធាត់ខ្លាំងពេក**
- **មិនមានការធ្វើលំហាត់ប្រាណ**

នរណាម្នាក់ក៏អាចមានរោគមហារីកពោះវៀនធំនេះដែរ ។ ទោះបីជារោគមហារីកពោះវៀនធំពី 20%-25% កើតឡើងចំពោះមនុស្សដែលមានប្រវត្តិគ្រួសារក៏ដោយ ក៏ករណីរោគមហារីកពោះវៀនធំប្រមាណ 75% កើតឡើងចំពោះមនុស្សដែលមិនមានកត្តាប្រថុយគ្រោះថ្នាក់ទាំងនេះផងដែរ ។

## រោគសញ្ញា

ជាធម្មតា គ្មានរោគសញ្ញាទេ តែរោគសញ្ញាមួយចំនួនអាចមានដូចជា :

- **រាគរូស ឬទល់លាមក**
- **ឈាមនៅក្នុង ឬនៅលើលាមក (ទាំងពណ៌ក្រហមស្រាល និងក្រហមដុត)**
- **ដុំលាមកតូចៗ**
- **មិនស្រួលក្រពះ (ហើមប៉ោង ណែន និងឬឈឺក្នុងពោះ)**
- **ឈឺអួចៗក្នុងពោះញឹកញាប់**
- **មានអារម្មណ៍ថាពោះវៀនណែនៗ**
- **ស្រកទម្ងន់ដោយមិនដឹងមូលហេតុ**

## ការបង្ការ/ការរកឃើញទាន់ពេល

ជាធម្មតា គ្មានរោគសញ្ញាណាមួយសម្រាប់រោគមហារីកពោះវៀនធំនោះទេ ។ ការពិនិត្យមើល ត្រូវបានណែនាំឱ្យធ្វើសម្រាប់មនុស្សមានអាយុ 50 ឆ្នាំ ឬលើសពីនេះ ។ ការពិនិត្យមួយក្នុងចំណោមការពិនិត្យរោគមហារីកក្រពះដែលគួរតែមានគឺ ការពិនិត្យមើលពោះវៀនធំ ។ ក្នុងកំឡុងពេលពិនិត្យមើលពោះវៀនធំ គ្រូពេទ្យប្រើបំពង់អាចបត់បានដែលមានភ្លើង និងកាម៉េរ៉ារូបភាពតូចមួយ ដើម្បីមើលខាងក្នុងពោះវៀនធំទាំងមូល ។ គំរូជាលិកាអាចត្រូវបានប្រមូលយក (ជីវជាលិកាសាស្ត្រ) និងការរីកធំមិនធម្មតា ឬ **ដុំសាច់** អាចត្រូវបានយកចេញក្នុងកំឡុងពេលវះកាត់ ។




## ការណែនាំពិនិត្យរោគមហារីកពោះវៀនធំ

ចាប់ពីអាយុ 50 ទាំងបុរស និងស្ត្រីគួរតែអនុវត្តតាមការណែនាំពិនិត្យទាំងនេះ :

- **តេស្តឈាមក្នុងលាមក (FOBT) រៀងរាល់ឆ្នាំ**
- **ពិនិត្យមើលពោះវៀនធំកន្លែងកោងរៀងរាល់ 5 ឆ្នាំម្តង**
- **ពិនិត្យមើលពោះវៀនធំរៀងរាល់ 10 ឆ្នាំម្តង**

## ការពិនិត្យរោគវិនិច្ឆ័យ និងការព្យាបាល

ការព្យាបាលផ្អែកតាមផ្អែកតាមដំណាក់កាលនៃរោគមហារីក ។ ជាទូទៅ ការព្យាបាលអាចមានដូចជា :

- **ការព្យាបាលតាមបែបគីមីសាស្ត្រ** ថ្នាំសម្លាប់កោសិការោគមហារីក
- **ការវះកាត់** ដើម្បីយកកោសិកាមហារីកចេញ
- **ការព្យាបាលដោយកាំរស្មី** ដើម្បីកំទេចជាលិកាដែលបង្ករជារោគមហារីក

## សន្និដ្ឋាន

រោគមហារីកពោះវៀនធំ គឺជារោគមហារីកច្រើនជាងគេបំផុតទីពីរនៅក្នុងសហរដ្ឋអាមេរិក ហើយជាមូលហេតុចម្បងទីបីនៃការស្លាប់ក្នុងចំណោមប្រជាអាមេរិកកាត់អាស៊ី ។ ការប្រថុយគ្រោះថ្នាក់ចំពោះការប្រែក្លាយជារោគមហារីកពោះវៀនធំ អាចកាត់បន្ថយបានយ៉ាងច្រើនដោយអនុវត្តតាមការណែនាំពិនិត្យរោគមហារីក និងដោយធ្វើការផ្លាស់ប្តូរដំងាយស្រួលក្នុងការតមអាហារ និងរបៀបរស់នៅ ។

### ចូរចងចាំថា ការរកឃើញទាន់ពេលជួយសង្គ្រោះជីវិតបាន !

សម្រាប់ព័ត៌មានបន្ថែមពីកម្មវិធីពិនិត្យរោគមហារីករបស់យើង សូម**ទូរស័ព្ទទៅលេខ 240-777-1409** ឬចូលទៅកាន់គេហទំព័ររបស់យើងតាម **www.AAHIinfo.org** ។

ប្រភព

***American Cancer Society*, *Cancer Research And Prevention Foundation*, *Colorectal Cancer Network, eMedicine Health, National Cancer Institute, WebMed***